# សារសំខាន់នៃចំណីត្រីផ្អាប់

កម្ពុជាយើងជាប្រទេសដែលសំបូរត្រីល្អិតទឹកសាបច្រើនជាងគេនៅក្នុងពិភពលោក ដែលមានផលចាប់ប្រមាណ ១៥០ ទៅ ២០០ពាន់តោនក្នុង១ឆ្នាំ។ ក៏ប៉ុន្តែត្រីល្អិត ទាំងនេះមានតែរយៈពេលខ្លី ២-៣ខែប៉ុណ្ណោះក្នុង១ឆ្នាំ។ ប្រជាជនដែល នៅតាមជនបទឆ្ងាយៗ ពិសេសតាមខេត្ត ដែលគ្មានដែនទនេសាទ តែងតែមកធ្វើប្រហុក ផ្អក ទឹកត្រី ឬផលិតផលកែច្នៃ ផ្សេងៗ ដើម្បីទុក សម្រាប់ហូបក្នុងរយះ ពេល១ឆ្នាំ ។ នៅតាមដាយត្រីល្អិតនៃដងទន្លេសាប នៅរដូវសំបូរត្រីល្អិតតម្លៃរបស់វាទាបជាងពេលធម្មតាពី ២-៥ ដង ។ ក្រៅពីការប្រើប្រាស់សម្រាប់ចំណីមនុស្ស ត្រីល្អិតក៏ត្រូវបានគេប្រើប្រាស់ដើម្បី ជាចំណី សម្រាប់វារីវប្បកម្ម និងការ ចិញ្ចឹមសត្វផងដែរ ដូចជាការ ធ្វើចំណីផ្អាប់ និងម្សៅត្រី។



## ការធ្វើចំណីត្រីផ្អាប់

ការធ្វើចំណីត្រីផ្អាប់មិនពិបាកទេ គឺយើងគ្រាន់តែមានពាង អាងស៊ីម៉ង់ ឬជីករណ្តៅក្រាលកៅស៊ូផ្លាស្ទិកដើម្បីផ្អាប់ត្រី ។ នៅពេលរដូវសំបូរត្រីល្អិត យើងអាចទិញត្រីល្អិតដែលមានតម្លៃថោកសល់ពីការធ្វើប្រហុកយកមកចាក់ផ្អាប់នៅក្នុងពាង អាង ឬរណ្តៅ ដោយដាក់ត្រីល្អិតជាស្រទាប់ៗឆ្លាស់គ្នាជាមួយ កន្ទក់ ។ គឺត្រូវក្រាលកន្ទក់នៅបាតរួចដាក់ត្រីល្អិត ឆ្លាស់គ្នា រហូតដល់ខាងលើបំផុតដាក់កន្ទក់ ដើម្បីការពារកុំឱ្យខ្លិនស្អុយ។ យើងអាចដាក់អំបិល ឬស្ករត្នោត១០-១៥ភាគរយ លាយ ជាមួយកន្ទក់ដើម្បីរក្សាចំណីផ្អាប់នេះបានយូ។






## ការប្រើប្រាស់ចំណីត្រីផ្អាប់

បន្ទាប់ពីផ្អាប់ទុកមួយរយៈពេលមក ត្រីល្អិត និងកន្ទក់នឹងកាច់គ្នាបានជាត្រីផ្អាប់។ ត្រីផ្អាប់មានសារធាតុចិញ្ចឹម និងប្រូតេអ៊ីនខ្ពស់ជាងត្រីល្អិតស្រស់ ដូចនេះយើង អាចយកវាតែ ១០-២០ភាគរយ ដើម្បីបបរលាយជាមួយនឹងកន្ទក់ កាកសំណល់ផ្ទះបាយ ឬបន្លែសេសសល់ប៉ុណ្ណោះ។ ដូចនេះដើម្បីបានចំណី ១០០គក្រ យើងប្រើត្រីផ្អាប់តែ ១០-២០គក្រ ទៅតាមប្រភេទត្រីដែលចិញ្ចឹម។



## សារសំខាន់នៃចំណីត្រីផ្អាប់

ការធ្វើចំណីត្រីផ្អាប់វាមានផលប្រយោជន៍ខ្លាំងណាស់ចំពោះអ្នកចិញ្ចឹមត្រី ជាពិសេសការចិញ្ចឹមត្រីអណ្ដែង ត្រីប្រា និងត្រីពោរ៍។ ព្រោះត្រីទាំងនេះវាត្រូវការស៊ីចំណីដែលមានសារធាតុចិញ្ចឹមខ្ពស់ និងមានប្រូតេអ៊ីនច្រើន ដូចនេះត្រីផ្អាប់អាចផ្ដល់នូវសារធាតុទាំងនោះបានដោយ មិនចាំបាច់ចំណាយត្រីច្រើនបើប្រៀបធៀបទៅនឹងការប្រើត្រីស្រស់ដើម្បីបបរលាយឱ្យចំណីត្រីនោះ ។ ជាទូទៅអ្នកចិញ្ចឹមត្រីតែងតែយក ត្រីស្រស់ប្រមាណពី ៦០-៧០ភាគរយដើម្បីបបរលាយឱ្យត្រីស៊ី ឬពេលសំបូរត្រីល្អិតអាចឱ្យវាស៊ីរហូតដល់ ១០០ភាគរយ ។ នេះគឺជាការ ខាតបង់យ៉ាងច្រើន បើយើងនៅតែបន្ថយកត្រីស្រស់មកឱ្យត្រីស៊ីទៀតនោះ ។ ការប្រើប្រាស់ចំណីត្រីផ្អាប់មានសារសំខាន់ជាច្រើនដូចជា :

១. កាត់បន្ថយការចំណាយទៅលើចំណីត្រី ព្រោះត្រីល្អិតនៅពេលដែលយកមកធ្វើត្រីផ្អាប់មានតម្លៃថោកជាងត្រីល្អិតស្រស់ ហើយចំនួននៃការដាក់ឱ្យស៊ីក៏តិចជាងត្រីស្រស់ដែរ

២. ការលូតលាស់របស់ត្រីធំលឿន និងមានការធន់នឹងជំងឺផ្សេងៗ ដោយសារត្រីផ្អាប់សំបូរសារធាតុចិញ្ចឹមផ្សេងៗជាច្រើន

៣. មិនចំណាយពេលវេលា មិនចាំបាច់ទិញ ឬចាប់ត្រីល្អិតជារៀងរាល់ថ្ងៃដើម្បីឱ្យចំណីត្រីហើយអាចយកពេលនេះទៅប្រកប មុខរបរអ្វីផ្សេងៗទៀតសម្រាប់ចិញ្ចឹមជីវិត

៤. ជួយកាត់បន្ថយសំពាធនេសាទទៅលើធនធានធម្មជាតិដែលកំពុងតែរងគ្រោះថ្នាក់ ។

## ការសន្និដ្ឋាន

ការធ្វើចំណីត្រីផ្អាប់មានសារសំខាន់ខ្លាំងណាស់ដល់ប្រជាជនកម្ពុជាទូទៅនិយាយជារួម និងអ្នកចិញ្ចឹមត្រីនិយាយដោយឡែក ពីព្រោះការ ធ្វើចំណីត្រីផ្អាប់នេះមិនត្រឹមតែជួយធ្វើឱ្យត្រីមានការលូតលាស់ឆាប់រហ័ស ធន់ជំងឺ ជួយកាត់បន្ថយចំណាយទៅលើចំណី និងចំណេញពេលប៉ុណ្ណោះទេ វាថែមទាំងជួយក្នុងការរួមចំណែកជួយថែរក្សានូវធនធានជលផលរបស់យើងថែមទៀតផង តាមរយៈការកាត់បន្ថយការ នេសាទត្រីល្អិតដើម្បីជាចំណីត្រីប្រចាំថ្ងៃ។ ព្រោះត្រីល្អិតដែលយើងចាប់ប្រចាំថ្ងៃនោះមិនមែនជាប្រភេទត្រីល្អិតសុទ្ធនោះទេ គឺវាជាកូនត្រីដែលមិនទាន់ធំ។ ចំពោះត្រីល្អិតដែលសុទ្ធនោះគឺវាមានតែនៅក្នុងរយៈពេល២-៣ខែ គឺពីចន្លោះខែ វិច្ឆិកា-មករាប៉ុណ្ណោះ។ ដូចនេះ ដើម្បីឱ្យធនធានជលផលយើងនៅតែសំបូរសម្រាប់មនុស្សជំនាន់ក្រោយៗទៀត យើងជាអ្នកនេសាទ និងអ្នកចិញ្ចឹមត្រី គួររួមគ្នាថែរក្សា និងនាំគ្នាធ្វើចំណីត្រីផ្អាប់នេះឱ្យបានគ្រប់ៗគ្នា ។

*រៀបរៀងដោយ បណ្ឌិត ព្រំ សុមានី*
*នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ*